ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបំបែកសង្កាត់ចោមចៅ នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំបែកសង្កាត់ចោមចៅ នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជា០៣ គឺ **សង្កាត់ចោមចៅទី១ សង្កាត់ចោមចៅទី២** និង**សង្កាត់ចោមចៅទី៣** ដូចខាងក្រោម៖

- សង្កាត់ចោមចៅទី១ មានភូមិចំនួន០៨ គឺ ភូមិគោកចំបក់ ភូមិទួលពង្រ ភូមិត្រពាំងរំចេក ភូមិចោមចៅ១ ភូមិត្រពាំងថ្លឹង១ ភូមិត្រពាំងថ្លឹង២ ភូមិត្រពាំងថ្លឹង៣ និងភូមិត្រពាំងថ្លឹង៤។

- សង្កាត់ចោមចៅទី២ មានភូមិចំនួន១៦ គឺ ភូមិថ្មគោល១ ភូមិថ្មគោល២ ភូមិថ្មគោល៣ ភូមិចោមចៅ២ ភូមិចោមចៅ៣ ភូមិជ្រៃកោង ភូមិល្វា ភូមិព្រៃល្វ ភូមិព្រៃស្តី ភូមិព្រែកកំបុត ភូមិដំណាក់ត្រយឹង ភូមិស្រែជំរៅ ភូមិកប់គង ភូមិក្រាំងជូនទៃ ភូមិព្រៃសណ្តែក និងភូមិព្រៃព្រីងខាងត្បូង១។
- សង្កាត់ចោមចៅទី៣ មានភូមិចំនួន១៤ គឺ ភូមិព្រៃទា១ ភូមិព្រៃទា២ ភូមិព្រៃជីសាក់ ភូមិត្រពាំងពោធិ៍ ភូមិព្រៃព្រីងខាងជើង១ ភូមិព្រៃព្រីងខាងជើង២ ភូមិព្រៃព្រីងខាងត្បូង២ ភូមិថ្នល់បំបែក ភូមិជម្ពូវ័ន១ ភូមិជម្ពូវ័ន២ ភូមិព្រៃស្វាយ ភូមិអង្គកែវ ភូមិអង្គ និងភូមិអូរជីម។

ព្រំប្រទល់រដ្ឋបាលសង្កាត់ចោមចៅទី១ សង្កាត់ចោមចៅទី២ និងសង្កាត់ចោមចៅទី៣ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ត្រូវបានផ្ទេរទីតាំងសាលាសង្កាត់ចោមចៅដែលស្ថិតនៅក្នុងភូមិថ្នល់បំបែក ទៅជាសាលាសង្កាត់ចោមចៅទី៣។

ទីតាំងសាលាសង្កាត់ចោមចៅទី១ ត្រូវស្ថិតនៅក្នុងភូមិត្រពាំងថ្លឹង១។

ទីតាំងសាលាសង្កាត់ចោមចៅទី២ ត្រូវស្ថិតនៅក្នុងភូមិក្រាំងជូនទៃ។

**មាត្រា៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅទី១ សង្កាត់ចោមចៅទី២ និងសង្កាត់ចោមចៅទី៣ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា៤.-**

ការបំបែកសង្កាត់ចោមចៅ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់ចោមចៅត្រូវបន្តគ្រប់គ្រងរដ្ឋបាលសង្កាត់ចោមចៅ រហូតដល់មានក្រុមប្រឹក្សាសង្កាត់ចោមចៅទី១ ក្រុមប្រឹក្សាសង្កាត់ចោមចៅទី២ និងក្រុមប្រឹក្សាសង្កាត់ចោមចៅទី៣ មកជំនួស។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ គណៈអភិបាលខណ្ឌពោធិ៍សែនជ័យ ក្រុមប្រឹក្សាសង្កាត់ចោមចៅ ក្រុមប្រឹក្សាសង្កាត់ចោមចៅទី១ ក្រុមប្រឹក្សាសង្កាត់ចោមចៅទី២ និងក្រុមប្រឹក្សាសង្កាត់ចោមចៅទី៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

